ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដាក់ឱ្យដំណើរការសេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

យោងតាមសំណើរបស់វិស័យឯកជននៅក្នុងក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន និងដើម្បីបង្កលក្ខណៈងាយស្រួល និងចំណេញពេលវេលាក្នុងការស្នើសុំសេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននាសម័យឧស្សាហកម្ម៤.០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងដាក់ឱ្យដំណើរការសេវាសាធារណៈពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម **ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១** ចំពោះសេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ថ្នាក់កណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នូវសេវាសាធារណៈ ដូចខាងក្រោម៖

- សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យការងារ https://lacms.mlvt.gov.kh
- សម្រាប់សេវាសាធារណៈពាក់ព័ន្ធវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ https://tvcms.mlvt.gov.kh
- សម្រាប់សេវាសាធារណៈពាក់ព័ន្ធជនបរទេស https://fwcms.mlvt.gov.kh

ដោយឡែក ចំពោះសេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គភាពច្រកចេញ-ចូលតែមួយរាជធានី ខេត្ត នឹងត្រូវឱ្យដាក់ដំណើរការ **ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២១** តទៅ។

ក្នុងរយៈពេលដំបូងនៃការដាក់ឱ្យដំណើរនេះ និយោជក និងកម្មករនិយោជិត ដែលមិនទាន់អាចស្នើសុំសេវាសាធារណៈតាមប្រព័ន្ធស្វ័យប្រវត្តិកម្មបាន អាចមកទទួលសេវាសាធារណៈដោយផ្ទាល់តាមអង្គភាពពាក់ព័ន្ធដដែល។

សម្រាប់ព័ត៌មានបន្ថែម សូមធ្វើការទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ **១២៩៧** ដោយឥតគិតថ្លៃ នៅរៀងរាល់ម៉ោងធ្វើការ។

ថ្ងៃ ពុធ ៨កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមករា ឆ្នាំ២០២១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩